# ការស្វែងរកមូលនិធិ (Fundraising)

## និយមន័យ

ការស្វែងរកមូលនិធិជា ដំណើរការស្វែងរកជំនួយ (ថវិកា មធ្យោបាយ សំភារៈ ជំនាញ ) ដើម្បីគាំទ្រអោយកម្មវិធី និងគំរោងអាចដំណើរការទៅបាន។ វាជាសកម្មភាព ដែលត្រូវធ្វើជាបន្តបន្ទាប់។ រាល់សកម្មភាពអង្គការ សុទ្ធតែរួមចំណែក (ផ្ទាល់ ឬមិនផ្ទាល់) ចំពោះការស្វែងរកមូលនិធិ។

ការស្វែងរកមូលនិធិមិនមែនជា៖

- ជាការសុំទានឡើយ ដូច្នេះ វាមិនមែនជារឿងអាក្រក់ ដែលអ្នកគ្រប់គ្រងអង្គការគួរអោយខ្មាស់អៀននោះទេ។
- ការរកថវិកា ដើម្បីធ្វើជាទ្រព្យសម្បត្តិ ឬសំរាប់មានបាន ផ្ទាល់ខ្លួនឡើយ។

## រកចំណូល តែមិនរកចំណេញ

អង្គការមិនអាចរកចំនេញបានទេ ព្រោះជារឿយៗគេតែង ប្រកាសថា ជាអង្គការមិនរកចំណេញ (non-profit) ប៉ុន្តែមិនមែនមានន័យថា អង្គការមិនអាចរកចំណូលនោះទេ ពោលគឺអាចរកចំណូលបាន។ ចំណូលដែលរកបាន ត្រូវប្រើប្រាស់លើចំណាយ ផ្សេងៗប្រកបដោយតំលាភាព សំរាប់គោលដៅអង្គការតែប៉ុណ្ណោះ។

ប្រភពថវិការបស់អង្គការមួយ:

- អ្នកផ្តល់មូលនិធិ (គ្រប់ប្រភេទ)
- សកម្មភាពរកចំណូលខ្លួនឯង (លក់ផលិតផល ឬសេវា)

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

# ការបង្កើតមូលដ្ឋានគ្រឹះសំរាប់ស្វែងរកថវិកា

## 1. ពង្រឹងគុណភាពកម្មវិធី/គំរោង

- រៀបចំគំរោងដោយមានការវិភាគ និងចូលរួមពីសហគមន៍
- អនុវត្តគំរោងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- បង្ហាញពីឥទ្ធិពលជាវិជ្ជមានរបស់គំរោង ចំពោះក្រុមគោលដៅ

## 2. ពង្រឹងសមត្ថភាពបុគ្គលិកជាបន្តបន្ទាប់

- ប៉ាន់ប្រមាណតំរូវការសមត្ថភាពបុគ្គលិក ជាបន្តបន្ទាប់
- បង្កើតយន្តការ និងគោលនយោបាយ សំរាប់អភិវឌ្ឍន៍សមត្ថភាពបុគ្គលិក
- បង្កើនសមត្ថភាពបុគ្គលិកជាប្រចាំ

## 3. ពង្រឹងសមត្ថភាពអង្គការជាបន្តបន្ទាប់

- ប៉ាន់ប្រមាណសមត្ថភាពអង្គការជាបន្តបន្ទាប់
- ពង្រឹងសមត្ថភាពអង្គការ ជាបន្តបន្ទាប់ ដូចជា៖
    - ពង្រឹងក្រុមប្រឹក្សាភិបាល  គោលការណ៍ គោលនយោបាយ ប្រព័ន្ធគ្រប់គ្រងនានា
    - ពង្រឹងការអនុវត្តគុណតំលៃ និងការកសាងក្រុម
    - ពង្រឹងទំនាក់ទំនង និងការប្រាស្រ័យទាក់ទងផ្ទៃក្នុង
    - ពង្រឹងការងារបណ្តាញ និងទំនាក់ទំនងខាងក្រៅ
    - សមត្ថភាពកសាងផែនការ  អនុវត្ត  ត្រួតពិនិត្យ និងវាយតំលៃ ។ល។

## 4. កសាងផែនការយុទ្ធសាស្ត្រ

- វិភាគស្ថានភាព ដែលមានការប្រែប្រួល និងវិភាគតំរូវការ (Niche)
- ធ្វើបច្ចុប្បន្នភាព ទស្សនៈ  បេសកកម្ម គោលដៅ  និងយុទ្ធសាស្ត្រអង្គការ

## 5. កសាងទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយ

- ស្វែងយល់ពីអ្នកផ្តល់ជំនួយ។ ណែនាំខ្លួន និងអង្គការដល់អ្នកផ្តល់ជំនួយ។

## 6. ស្វែងយល់ពីជំរើសផ្សេងៗក្នុងការស្វែងរកថវិកា

- ប្រើសំណើថវិកា? ប្រើព្រឹត្តិការណ៍ផ្សេងៗដើម្បីរៃអង្គាស?  សកម្មភាពរកចំនួល?

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

# ជំហាននានា ក្នុងការស្វែងរកថវិកា

1. កំនត់អ្នកទទួលបន្ទុកស្វែងរកថវិកា (នរណា?)
2. កំនត់ធនធានដែលអង្គការអ្នកត្រូវការ (លុយ សំភារៈ មនុស្ស?)
3. ស្វែងរកព័ត៌មាន និងអ្នកផ្តល់ជំនួយសក្តានុពល
4. សិក្សាលំអិតពីអ្នកផ្តល់ជំនួយ ដែលទំនងជានឹងត្រូវតាមគំរោងអ្នក
5. សរសេរសំណើប្រកបដោយគុណភាព និងដាក់សំណើតាមកាលកំនត់។ តាមដានក្រោយពេលដាក់សំណើ។
6. រៀនសូត្រពីសំណើដែលមិនបានជោគជ័យ
7. សរសេររបាយការណ៍ប្រកបដោយគុណភាព (បង្ហាញពីការប្រែប្រួលជាវិជ្ជមាន ក្នុងសហគមន៍គោលដៅរបស់អ្នក)

*បញ្ជាក់: មានសំណើប្រហែល ១០%ប៉ុណ្ណោះ ដែលទទួលបានថវិកា។ ដូច្នេះ ប្រសិនបើមិនបានជោគជ័យ សូមកុំបោះបង់ការព្យាយាម។*

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.